**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ......សហវ.

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ......១១៣៦......
ថ្ងៃទី១០...០៤...២០...
បញ្ជូន......................

ថ្ងៃ........ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ...... ខែ ...... ឆ្នាំ ២០២០

**ប្រកាស**
**ស្តីពី**
**ការបង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ សម្រាប់ពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ដល់សំណង់, ផ្ទះសម្បែង, ដីធ្លី ដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិផ្សេងទៀត របស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីផលិតកម្មដោយភាគរៈបរិស្ថាន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះ-ស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១.**- បង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍សម្រាប់ពិនិត្យ និងវាយ-តម្លៃលើផលប៉ះពាល់ដល់សំណង់, ផ្ទះសម្បែង, ដីធ្លី ដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីផលិតកម្មដោយភាគរៈបរិស្ថាន ស្ថិតក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ និងខេត្តកំពត។

**ប្រការ ២.**- គណៈកម្មការអន្តរក្រសួងមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តម **ញាណា ឡេង** . អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន



Scanned with CamScanner

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

| | | |
|---|---|---|
| ២-ឯកឧត្តម **អ៊ុម សិទ្ធីរ៉ា** | អគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម **ឌុច ចនធីត្ន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤-លោក **ញាន ចណ្ណា:** | អគ្គនាយករង នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក **ស្រ៊ាង លឹមស្រុយ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោកបណ្ឌិត **សំ ឆោមសទ្ធា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧-លោក **អ៊ុច ចណ្ណា** | អគ្គនាយករងបច្ចេកទេស និងជាប្រធានគ្រប់គ្រងគម្រោង នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨-លោក **ស៊ន់ សេរីវឌ្ឍន:** | ប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី ២ នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក **គង់ រដ្ឋា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុង និងគ្រប់គ្រងទិន្នន័យ នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០-លោក **ពិន និលឡា** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១-លោក **កែវ សុវត្ថិភាព** | អនុប្រធាននាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក និងជាមន្ត្រីបន្ទុកការងារបរិស្ថាន នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |

**ប្រការ ៣.-** គណៈកម្មការអន្តរក្រសួងមានភារកិច្ចចុះពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិ និងចូលរួមធ្វើការវាយតម្លៃលើផលប៉ះ-ពាល់ដល់សំណង់, ផ្ទះសម្បែង, ដីធ្លី ដើមឈើហូបផ្លែ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ប្រជាពលរដ្ឋទទួលរងផលប៉ះពាល់ដោយសារគម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន ស្ថិតក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តតាកែវ និងខេត្តកំពតឱ្យបានច្បាស់លាស់ដើម្បីជាមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចនូវកញ្ចប់ថវិកាសម្រាប់ឧបត្ថម្ភជាគោលនយោបាយជូនប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងខាងលើ។ គណៈកម្មការអន្តរក្រសួង បំពេញភារកិច្ចផ្អែកលើប្លង់បច្ចេកទេសសាងសង់លម្អិតដែលបានអនុម័តដោយក្រសួង-ស្ថាប័នអនុវត្តគម្រោង។

**ប្រការ ៤.-** គណៈកម្មការអន្តរក្រសួង មានសិទ្ធិបង្កើតក្រុមការងារសម្រាប់បំពេញការងារប្រចាំថ្ងៃបម្រើឱ្យគម្រោងខាងលើ។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីកាលបរិច្ឆេទចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>**ចម្លងជូន:**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ដូចប្រការ ៥ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ



Scanned with CamScanner